**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧.០៩-០៣៤ ប្រ.ក.

# ប្រកាស

## ស្តីពី

## ការធ្វើចំណាត់ថ្នាក់ និងសំវិធានធនលើទ្រព្យសកម្ម របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

## ទេសាភិបាល ធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ស្តីពីការប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា១៤ និង មាត្រា៥៧ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៨/៥២៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការតែងតាំង **ឯកឧត្តម ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា មានឋានៈស្មើ ទេសរដ្ឋមន្ត្រី
- យោងតាមស្មារតីនៃអង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០៩

## ស ម្រេ ច

## ជំពូក ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងធានាថា រាល់ឥណទាន និងទ្រព្យសកម្មទាំងអស់របស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ តទៅនេះហៅថា "គ្រឹះស្ថាន" ត្រូវបានវាយតម្លៃយ៉ាងទៀងទាត់ ដោយប្រើប្រព័ន្ធធ្វើចំណាត់ថ្នាក់ដ៏ប្រុងប្រយ័ត្ន និងធានាថាបានធ្វើសំវិធានធន និងលុបចេញពីបញ្ជី បានទាន់ពេលវេលា

និងសមស្រប នៅក្នុងគណនីសំវិធានធនឥណទានបាត់បង់ ដើម្បីឆ្លុះបញ្ចាំងពីស្ថានភាពពិតនិងលទ្ធផល នៃប្រតិបត្តិការរបស់គ្រឹះស្ថាន។

ប្រកាសនេះអនុវត្តចំពោះរាល់ឥណទាន និងបុរេប្រទាន និងទ្រព្យសកម្មដែលមានលក្ខណៈប្រហាក់ប្រហែល រួមបញ្ចូលទាំង ឥណទានដែលផ្តល់ដល់បុគ្គលសម្ព័ន្ធ និងសម្ព័ន្ធញាតិផងដែរ ដែលមាននៅក្នុងតារាងតុល្យការរបស់គ្រឹះស្ថាន។

ក្នុងករណីដែលឥណទានមិនដំណើរការជះឥទ្ធិពលលើ សាធនភាព សាច់ប្រាក់ងាយស្រួល ស្ថានភាពចំណូលនៃធនាគារ អ្នកគ្រប់គ្រងជាន់ខ្ពស់ និងក្រុមប្រឹក្សាភិបាលត្រូវធ្វើការវិនិច្ឆ័យមួយ ផ្អែកលើហានិភ័យ និងសំឡឹងទៅមុខដោយគិតអំពីនិន្នាការនៃចំណាត់ថ្នាក់ទ្រព្យសកម្ម។

**ប្រការ ២.-**

**"មូលធនកម្មការប្រាក់"** មានន័យថារាល់ការបង្គរ និងការប្រាក់មិនអាចប្រមូលបានដែលត្រូវបូកបញ្ចូលក្នុងប្រាក់ដើមនៃឥណទាននៅថ្ងៃទូទាត់សងប្រាក់ ឬ ថ្ងៃឥណប្រតិទាន។ មូលធនកម្មការប្រាក់ក៏ត្រូវរួមបញ្ចូលផងដែរនូវការប្រាក់មិនបានទូទាត់លើហិរញ្ញប្បទានជាថ្មីឡើងវិញនៃឥណទាន។

សម្រាប់គោលបំណងនៃប្រកាសនេះ មិនអនុញ្ញាតឱ្យធ្វើមូលធនកម្មការប្រាក់ឡើយ លើកលែងតែ :

- អ្នកខ្ចីមានសមត្ថភាពក្នុងការទូទាត់សងបំណុលទាំងស្រុង (ប្រាក់ដើមបូកការប្រាក់) ក្នុងស្ថានភាពអាជីវកម្មធម្មតា
- មូលធនកម្មការប្រាក់ត្រូវបានគិតជាមុននាពេលអនុម័តឥណទានដំបូង ដោយផ្អែកលើផែនការកង្វះលំហូរសាច់ប្រាក់ជាបណ្តោះអាសន្នរបស់អ្នកខ្ចី
- ការទូទាត់សងរួមបញ្ចូលទាំងមូលធនកម្មការប្រាក់ផង គឺផ្អែកលើព្រឹត្តិការណ៍អនាគតជាក់លាក់ដែលអាចជឿជាក់បាន។

**"ដំណើរការនៃការប្រមូល"** មានន័យថាការប្រមូលបំណុលត្រូវដំណើរការ តាមលំដាប់ពេលវេលាដែលបានកំណត់ជាក់លាក់តាមរយៈ ÷

- បណ្តឹងទៅតុលាការ រួមទាំងការកាត់សេចក្តីប្រឆាំងអ្នកខ្ចី ឬ
- តាមរយៈការខិតខំប្រមូលបំណុល ដោយមិនប្តឹងទៅតុលាការ ប៉ុន្តែ រំពឹងថាបំណុលនោះនឹងទទួលបានការទូទាត់សងយ៉ាងពេញលេញក្នុងកំឡុងពេល៩០ថ្ងៃ ឬ ស្តារបំណុលនោះឱ្យមកនៅស្ថានភាពបច្ចុប្បន្ន តាមរយៈការទូទាត់សងនូវចំនួនដែលនៅសល់។

**"ឥណទាន និងបុរេប្រទាន"** អាចត្រូវបានប្រើឆ្លាស់គ្នា រួមមានឥណទាន អប្បហារ បុរេប្រទាន ឥណទានវិបារូបន៍ រូបិយាណត្តិនាំចេញដែលបានទិញ ផលប័ត្រត្រូវទទួល ឬ បានទិញ ឬ រូបិយាណត្តិ

នាំចូល កាតព្វកិច្ចរបស់អតិថិជនលើស៊ីការ (Acceptances) ឬ ឧបករណ៍ឥណទានផ្សេងទៀតដែលបានផ្តល់ដល់អតិថិជននៃគ្រឹះស្ថានមួយ ។

"**ទ្រព្យសកម្មមិនដំណើរការ**" មានន័យថាទ្រព្យសកម្មដែលលែងមានចំណូល ។ សម្រាប់គោលបំណងនៃប្រកាសនេះ "ទ្រព្យសកម្មមិនដំណើរការ" ត្រូវបានចាត់ថ្នាក់ក្រោមស្តង់ដារ សង្ស័យ ឬ បាត់បង់ ។

គណនីចរន្ត ដែលប្រើក្រោមរូបភាពជាឥណទានវិបារូបន៍ និងការពន្យារពេលឥណទានផ្សេងទៀត ដែលមិនបានរៀបចំជាមុននូវកាលវិភាគទូទាត់សងត្រូវបានចាត់ទុកថា "**មិនដំណើរការ**" នៅពេលដែលស្ថានភាពណាមួយ ក្នុងចំណោមស្ថានភាពដូចខាងក្រោមកើតមានឡើង :

- បំណុលរបស់អតិថិជនប្រើប្រាស់លើសពីកម្រិតអនុម័តក្នុងរយៈពេល ៩០ថ្ងៃបន្តបន្ទាប់គ្នា ឬ ច្រើនជាងនេះ
- ឥណទានរបស់អតិថិជនហួសកាលកំណត់លើសពី ៩០ ថ្ងៃ ឬ ច្រើនជាងនេះ
- អតិថិជនមិនបានបង់ការប្រាក់តាមកាលកំណត់បង់ក្នុងរយៈពេល ៩០ ថ្ងៃ ឬ ច្រើនជាងនេះ ឬ
- គណនីចរន្តមិនមានសកម្មភាពក្នុងរយៈពេល ៩០ ថ្ងៃ ឬ មិនមានប្រាក់បញ្ញើគ្រប់គ្រាន់សម្រាប់សងការប្រាក់ដែលជំពាក់ក្នុងកំឡុងពេលប្រើប្រាស់ឥណទាន ។

"**ខ្ទង់ក្រៅតារាងតុល្យការ** " មានន័យថាខ្ទង់ទាំងឡាយណាដែលមិនបានបង្ហាញនៅក្នុងតារាងតុល្យការ ប៉ុន្តែនាំឱ្យមានហានិភ័យឥណទាន ។ ហានិភ័យទាំងនោះរួមមាន ការធានា ការធ្វើស៊ីការ ការធានាលើប្រតិបត្តិការ លិខិតឥណទាន និងខ្ទង់ក្រៅតារាងតុល្យការផ្សេងទៀត ដែលធនាគារជាតិនៃកម្ពុជាកំណត់ថាអាចនាំឱ្យមានហានិភ័យឥណទាន ។

"**ហួសកាលកំណត់ ឬ លើសកាលកំណត់** " មានន័យថា ឥណទានដែល :

- អតិថិជនមិនបានបង់ប្រាក់ដើម ឬ ការប្រាក់តាមកាលកំណត់រយៈពេល ៣០ ថ្ងៃ ឬ ច្រើនជាងនេះ ឬ
- ចំនួនការប្រាក់ ដែលស្មើនឹងការប្រាក់បង្គរក្នុងរយៈពេល ៣០ ថ្ងៃ ឬ ច្រើនជាងនេះ ត្រូវបានបញ្ចូលជាប្រាក់ដើម ធ្វើបុនហិរញ្ញប្បទាន ឬ បង្វិលជាឥណទានថ្មី ។

គណនីចរន្ត ដែលប្រើក្រោមរូបភាពជាឥណទានវិបារូបន៍ និងការពន្យារពេលឥណទានផ្សេងទៀតដែលមិនមានរៀបចំជាមុននូវកាលវិភាគទូទាត់សង ត្រូវចាត់ទុកថាហួសកាលកំណត់នៅពេលដែលមានស្ថានភាពណាមួយខាងក្រោមនេះ :

- អតិថិជនបានប្រើឥណទានលើសកម្រិតអនុម័តរយៈពេល ៣០ ថ្ងៃ ជាប់ៗគ្នា ឬ ច្រើនជាងនេះ
- ឥណទានរបស់អតិថិជនហួសកាលកំណត់ប្រើរយៈពេល ៣០ ថ្ងៃ ឬ ច្រើនជាងនេះ

- អតិថិជនមិនបានបង់ការប្រាក់រយៈពេល ៣០ថ្ងៃ ឬច្រើនជាងនេះ
- គណនីចរន្តមិនមានសកម្មភាពរយៈពេល ៣០ ថ្ងៃ ឬ ប្រាក់បញ្ញើនៅក្នុងគណនីនោះ មិនគ្រប់គ្រាន់សម្រាប់ទូទាត់ការប្រាក់បញ្ចូលជាប្រាក់ដើម នៅក្នុងគ្រាប្រើប្រាស់ឥណទាន។

"**ចំណាយសំវិធានធនសម្រាប់ឥណទានបាត់បង់**" មានន័យថា ជាគណនីមួយនៃរបាយការណ៍ចំណេញ-ខាតដែលត្រូវបានប្រើប្រាស់ដើម្បីបង្កើន ឬបន្ថយសំវិធានធនឥណទានបាត់បង់ក្នុងតារាងតុល្យការ ដើម្បីរក្សាគណនីនោះនៅកម្រិតមួយគ្រប់គ្រាន់សម្រាប់ស្រូបយកការខាតបង់ដែលបានគិតទុកនៅក្នុងសំពៀតឥណទាន។

"**សំវិធានធនសម្រាប់ឥណទានបាត់បង់**" មានន័យថា ជាគណនីមួយនៃតារាងតុល្យការដែលបង្កើតឡើងសម្រាប់ការចំណាយសំវិធានធននៅក្នុងរបាយការណ៍ចំណេញ-ខាត និងសម្រាប់កាត់កងជាមួយចំណែកឥណទានបាត់បង់ដែលត្រូវលុបចោល។ គណនីសំវិធានធនឥណទានបាត់បង់ត្រូវកាត់កងជាមួយឥណទានដុលសម្រាប់គោលបំណងនៃការធ្វើរបាយការណ៍ហិរញ្ញវត្ថុ។

"**ឥណទានរៀបចំឡើងវិញ**" មានន័យថាឥណទានដែលត្រូវបានធ្វើការកែប្រែកាលកំណត់សង ឬធ្វើហិរញ្ញប្បទានឡើងវិញ ស្របតាមកិច្ចសន្យាដែលកំណត់ការទូទាត់សងទៅតាមគ្រាជាថ្មីដោយសារភាពទន់ខ្សោយនៃស្ថានភាពហិរញ្ញវត្ថុរបស់កូនបំណុល និង/ឬ កង្វះលទ្ធភាពក្នុងការទូទាត់សងឥណទានដូចដែលបានព្រមព្រៀងពីដំបូង។

## ជំពូក ២
## ការធ្វើចំណាត់ថ្នាក់ឥណទាន និងទ្រព្យសកម្ម

**ប្រការ ៣.-**

គ្រប់ឥណទាន និងទ្រព្យសកម្មទាំងអស់ត្រូវបានចាត់ថ្នាក់ដោយផ្អែកទៅលើសមត្ថភាពសងរបស់សមាជិក។ សមត្ថភាពសងនេះ ត្រូវបានវាយតម្លៃតាមរយៈលក្ខណៈវិនិច្ឆ័យដូចខាងក្រោម :

- ប្រវត្តិនៃការទូទាត់សង
- ស្ថានភាពហិរញ្ញវត្ថុរបស់អ្នកខ្ចីនាពេលបច្ចុប្បន្ន និងនៅពេលអនាគត
- គម្រោងលំហូរសាច់ប្រាក់ និងអាជីវកម្មសម្រាប់អនាគតដែលផ្អែកលើសម្មតិកម្មជាក់ស្តែង និងប្រុងប្រយ័ត្ន
- លទ្ធភាព និងឆន្ទៈក្នុងការសងត្រឡប់មកវិញរបស់អ្នកខ្ចី
- បរិស្ថានហិរញ្ញវត្ថុ និង
- គុណភាពនៃការរៀបចំឯកសារ។

ករណីប្រភពដំបូងនៃការទូទាត់សងមិនអាចធានាបានចំពោះការទូទាត់សង ឥណទានអាចត្រូវបានធ្វើចំណាត់ថ្នាក់ជាឥណទានឃ្លាំមើល ឬមិនដំណើរការ ទោះបីជាឥណទាននោះមានលក្ខណៈចរន្ត ឬអាចនឹងត្រូវទូទាត់ដោយវត្ថុធានាក៏ដោយ។ ការធ្វើចំណាត់ថ្នាក់ឡើងវិញក៏អាចធ្វើផងដែរ ប្រសិនបើសមភាគីមិនអាចបំពេញតាមលក្ខខណ្ឌដើមនៃការទូទាត់សង ឬ បើឥណទានដែលដំណើរការមិនល្អនោះត្រូវបានដោះស្រាយដោយបច្ចេកទេសនៃការផ្លាស់ប្តូរលក្ខខណ្ឌ បុនហិរញ្ញប្បទាន ឬ បុរេប្រទានបន្ថែម។

ក្នុងករណីដែល ការធ្វើចំណាត់ថ្នាក់នីមួយៗនៃឥណទានផ្អែកលើលក្ខណៈវិនិច្ឆ័យមិនច្បាស់លាស់ ការធ្វើចំណាត់ថ្នាក់ដ៏តឹងរឹងជាងនេះត្រូវតែអនុវត្ត។ ការចាត់ថ្នាក់ឥណទានមិនកម្រិតត្រឹមតែនិយមន័យដូចមានចែងក្នុងប្រការ ៤ ខាងក្រោមនេះទេ។ ក្នុងករណីដែលការវិភាគស្ថានភាពហិរញ្ញវត្ថុ សមត្ថភាព និងឆន្ទៈសងត្រឡប់មកវិញរបស់អ្នកខ្ចីបានបង្ហាញឱ្យឃើញថាមានស្ថានភាពធ្ងន់ធ្ងរ នោះចំណាត់ថ្នាក់ឥណទានត្រូវធ្វើឡើងឱ្យកាន់តែមានភាពតឹងរឹងបន្ថែមទៀត។

**ប្រការ ៤.-**

រាល់ទ្រព្យសកម្មត្រូវតែចាត់ថ្នាក់ជា ៥ ប្រភេទ ដូចខាងក្រោម៖

១- **ធម្មតា** : ទ្រព្យសកម្មប្រភេទនេះត្រូវបានធានាទាំងស្រុងដោយទ្រព្យសម្បត្តិ និងសមត្ថភាពទូទាត់សងរបស់សមភាគីនាពេលបច្ចុប្បន្ន និងជាទ្រព្យសកម្មកំពុងដំណើរការ ដោយអនុលោមទៅតាមកិច្ចសន្យា និងរំពឹងថានៅតែបន្តដំណើរការបែបនេះរហូតតទៅ។

២- **ឃ្លាំមើល** (Watch) : ទ្រព្យសកម្មប្រភេទនេះនឹងត្រូវបានធានា និងមិនទាន់ហួសកាលកំណត់សង ប៉ុន្តែមានចំណុចខ្សោយខ្លះដែលជាសក្តានុពលនឹងធ្វើឱ្យគុណភាពទ្រព្យសកម្មចុះខ្សោយ ឬនាំឱ្យស្ថានភាពគ្រេះថ្នាក់មិនត្រូវបានការពារនៅពេលណាមួយខាងមុខ បើចំណុចខ្សោយទាំងនោះមិនត្រូវបានកែតម្រូវទេនោះ។ ឧទាហរណ៍ខ្លះៗនៃចំណុចខ្សោយទាំងនោះរួមមាន ភាពគ្មានលទ្ធភាពត្រួតពិនិត្យឱ្យបានសមស្រប ដោយសារតែកិច្ចសន្យាខ្ចីប្រាក់មានចន្លោះប្រហោង ភាពអន់ថយនៃស្ថានភាព ឬ ការគ្រប់គ្រងវត្ថុបញ្ចាំ ការធ្លាក់ចុះនៃស្ថានភាពសេដ្ឋកិច្ច ឬ និន្នាការចុះខ្សោយនៃស្ថានភាពហិរញ្ញវត្ថុរបស់អ្នកខ្ចី ហើយបើមិនបានត្រួតពិនិត្យទេនឹងនាំឱ្យខូចខាតដល់សមត្ថភាពទូទាត់សង រួមទាំងហានិភ័យដែលអាចកើតមានឡើងធំជាងហានិភ័យដែលបានគិតនាពេលចាប់ផ្តើមផ្តល់ឥណទាន។ ឥណទានប្រភេទនេះមិនគួរប្រើប្រាស់ជាការសម្របសម្រួលនៅពេលចាត់ថ្នាក់រវាងឥណទានធម្មតា និង

ឥណទានក្រោមស្តង់ដារទេ។

ឥណទានវិបារូបនី ត្រូវចាត់ថ្នាក់ " ការឃ្លាំមើល " ប្រសិនបើ ប្រើលើសកម្រិតអនុម័ត ច្រើនជាង ៣០ថ្ងៃ ប៉ុន្តែតិចជាង ៩០ថ្ងៃ ឬប្រសិនបើគណនីចរន្តមិនមានសកម្មភាពរយៈពេល ៣០ ថ្ងៃ ឬ ប្រាក់បញ្ញើនៅក្នុងគណនីនោះមិនគ្រប់គ្រាន់សម្រាប់ទូទាត់ការប្រាក់បញ្ចូលជាប្រាក់ដើមនៅក្នុងគ្រាប្រើប្រាស់ឥណទាន។

ឥណទានណាដែលហួសកាលកំណត់សងចំនួន ៣០ ថ្ងៃ ឬ លើសពីនេះ ប៉ុន្តែតិចជាង ៩០ ថ្ងៃ ត្រូវចាត់ថ្នាក់ប្រភេទឃ្លាំមើល ឬ អន់ជាងនេះ។

នៅពេលដែលការទូទាត់សងការប្រាក់សម្រាប់រយៈពេលពី ៣០ ថ្ងៃ ទៅ ៩០ ថ្ងៃ ត្រូវបាន បញ្ចូលទៅជាប្រាក់ដើម ធ្វើបុនហិរញ្ញប្បទាន ឬបង្វិលជាឥណទានថ្មី (rolled over loans) ឥណទាន នេះត្រូវចាត់ថ្នាក់ជាឥណទានឃ្លាំមើល ឬ អន់ជាងនេះ។

៣- **ក្រោមស្តង់ដារ** : ទ្រព្យសកម្មប្រភេទនេះមិនត្រូវបានការពារគ្រប់គ្រាន់ដោយ ទ្រព្យសម្បត្តិ និងសមត្ថភាពសងបំណុលរបស់សមភាគីឡើយ។ ជាពិសេស ប្រភព ធនធានចំបងសម្រាប់សងបំណុលមានមិនគ្រប់គ្រាន់ដើម្បីសងបំណុលដែលធនាគារ ត្រូវតែសំឡឹងមើលទៅប្រភពធនធានបន្ទាប់ដូចជា វត្ថុបញ្ចាំ ការលក់អចលនទ្រព្យ បុនហិរញ្ញប្បទាន ឬ ក៏ការបំពេញទុនបន្ថែមសម្រាប់ទូទាត់បំណុល។ ឥណទាន ក្រោមស្តង់ដារបានបង្ហាញយ៉ាងច្បាស់នូវចំណុចខ្សោយ ដែលធ្វើឱ្យប៉ះពាល់ដល់ ការទូទាត់សងបំណុលត្រឹមត្រូវតាមលំដាប់លំដោយ។

ឥណទានវិបារូបនី ត្រូវចាត់ថ្នាក់ " ក្រោមស្តង់ដារ " ប្រសិនបើ ប្រើលើសកម្រិតអនុម័តច្រើន ជាង ៩០ថ្ងៃ ឬឥណទានវិបារូបនីដែលមានចំនួនប្រាក់តិចតួចនៅខ្ទង់ឥណទានក្នុងរយៈពេល ៩០ថ្ងៃ ឬ លើសពីនេះ ឬប្រសិនបើគណនីចរន្តមិនមានសកម្មភាពរយៈពេល ៩០ ថ្ងៃ ឬ ប្រាក់បញ្ញើនៅក្នុងគណនី នោះមិនគ្រប់គ្រាន់សម្រាប់ទូទាត់ការប្រាក់បញ្ចូលជាប្រាក់ដើមនៅក្នុងគ្រាប្រើប្រាស់ឥណទាន។

ឥណទានដែលហួសកាលកំណត់សងចំនួន ៩០ ថ្ងៃ ឬ លើសពីនេះ ប៉ុន្តែតិចជាង ១៨០ ថ្ងៃ ត្រូវ ចាត់ថ្នាក់យ៉ាងទាបបំផុតក្រោមស្តង់ដារ។

នៅពេលដែលការទូទាត់សងការប្រាក់សម្រាប់រយៈពេលពី ៩០ ថ្ងៃ ទៅ ១៨០ ថ្ងៃ ត្រូវបាន បញ្ចូលទៅជាប្រាក់ដើម ធ្វើបុនហិរញ្ញប្បទាន ឬ បង្វិលជាឥណទានថ្មី ( rolled over loans ) ឥណទាននេះ ត្រូវចាត់ថ្នាក់ជាឥណទានក្រោមស្តង់ដារ ឬ អន់ជាងនេះ។

៤- **សង្ស័យ** : ទ្រព្យសកម្មប្រភេទនេះ មានចំណុចខ្សោយដូចឥណទានក្រោមស្តង់ដារ ដោយបូកបន្ថែមលក្ខខណ្ឌដែលឥណទានមិនមានការធានាបានល្អ។ យោងតាម

ហេតុការណ៍ ជាក់ស្តែង ស្ថានភាព និងតម្លៃចំណុចខ្សោយទាំងនេះ បាននាំឱ្យមានការសង្ស័យថា ឥណទានមិនអាចប្រមូលបានមកវិញទាំងស្រុងទេ។ លទ្ធភាពបាត់បង់មានកម្រិតខ្ពស់ ប៉ុន្តែ ដោយសារតែមានការរង់ចាំលើព្រឹត្តិការណ៍ជាក់លាក់ និងសមស្របណាមួយដែលនឹងកាត់បន្ថយកម្រិតបាត់បង់នោះ បរិមាណពិតប្រាកដនៃបំណុលដែលត្រូវបាត់បង់មិនអាចកំណត់បានទាំងស្រុង។ បើព្រឹត្តិការណ៍ដែលរង់ចាំនោះមិនបានកើតឡើងក្នុងរយៈពេល ១៨០ ថ្ងៃ ហើយការទូទាត់សងត្រូវបានពន្យារពេលបន្ថែមទៀត នោះការចាត់ថ្នាក់ទៅជាឥណទានបាត់បង់ត្រូវតែអនុវត្ត។

ឥណទានវិបារូបន៍ ត្រូវចាត់ថ្នាក់ " សង្ស័យ " ប្រសិនបើ ប្រើលើសកម្រិតអនុម័ត ច្រើនជាង ១៨០ថ្ងៃ ឬឥណទានវិបារូបន៍ដែលមានចំនួនប្រាក់តិចតួចនៅខ្វះឥណទានក្នុងរយៈពេល ១៨០ថ្ងៃ ឬ លើសពីនេះ ឬប្រសិនបើគណនីចរន្តមិនមានសកម្មភាពរយៈពេល ១៨០ ថ្ងៃ ឬប្រាក់បញ្ញើនៅក្នុងគណនីនោះមិនគ្រប់គ្រាន់សម្រាប់ទូទាត់ការប្រាក់បញ្ចូលជាប្រាក់ដើមនៅក្នុងគ្រាប្រើប្រាស់ឥណទាន។

ឥណទានណាមួយដែលហួសកាលកំណត់សងចំនួន ១៨០ ថ្ងៃ ឬ លើសពីនេះត្រូវចាត់ថ្នាក់យ៉ាងទាបបំផុតជាបំណុលសង្ស័យ ឬអន់ជាងនេះ។

នៅពេលការទូទាត់សងការប្រាក់សម្រាប់រយៈពេលពី ១៨០ ទៅ ៣៦០ ថ្ងៃ ត្រូវបានបញ្ចូលក្នុងប្រាក់ដើម ធ្វើបុនហិរញ្ញប្បទាន ឬ បង្វិលជាឥណទានថ្មី (rolled over loans) ឥណទាននេះត្រូវចាត់ថ្នាក់ជាបំណុលសង្ស័យ ឬ អន់ជាងនេះ។

**៥- បាត់បង់** : ទ្រព្យសកម្មទាំងឡាយណាដែលត្រូវបានចាត់ទុកថាមិនអាចប្រមូលមកវិញបាន ឬ នៅមានតម្លៃតិចតួច ត្រូវចាត់ថ្នាក់ជាបំណុលបាត់បង់។ ការខាតបង់ត្រូវទទួលស្គាល់ក្នុងអំឡុងពេលដែលឥណទានទាំងនោះត្រូវបានរកឃើញថា មិនអាចប្រមូលបាន។

ឥណទានវិបារូបន៍ ត្រូវចាត់ថ្នាក់ " បាត់បង់ " ប្រសិនបើ ប្រើលើសកម្រិតអនុម័ត ច្រើនជាង ៣៦០ថ្ងៃ ឬឥណទានវិបារូបន៍ដែលមានចំនួនប្រាក់តិចតួចនៅខ្វះឥណទានក្នុងរយៈពេល ៣៦០ថ្ងៃ ឬ លើសពីនេះ ឬ ប្រសិនបើគណនីចរន្តមិនមានសកម្មភាពរយៈពេល ៣៦០ ថ្ងៃ ឬ ប្រាក់បញ្ញើនៅក្នុងគណនីនោះមិនគ្រប់គ្រាន់សម្រាប់ទូទាត់ការប្រាក់បញ្ចូលជាប្រាក់ដើមនៅក្នុងគ្រាប្រើប្រាស់ឥណទាន។

ឥណទានណាមួយដែលហួសកាលកំណត់សងចំនួន ៣៦០ ថ្ងៃ ឬ លើសពីនេះត្រូវចាត់ថ្នាក់ជាឥណទានបាត់បង់។

នៅពេលការទូទាត់សងការប្រាក់សម្រាប់រយៈពេល ៣៦០ ថ្ងៃ ឬ លើសពីនេះត្រូវបានបញ្ចូល

ក្នុងប្រាក់ដើម ធ្វើប្តូរហិរញ្ញប្បទាន ឬ បង្វិលជាឥណទានថ្មី (rolled over loans) ឥណទាននេះត្រូវចាត់ថ្នាក់ជាបំណុលបាត់បង់។

**ប្រការ ៥.-**

ឥណទានវិបារូបន៍ ទោះជាមានរយៈពេលប្រសិទ្ធភាពយ៉ាងណាក៏ដោយ ត្រូវតែបានប្រើប្រាស់សម្រាប់ហិរញ្ញប្បទានរយៈកាលខ្លីតែប៉ុណ្ណោះ។ ឥណទានវិបារូបន៍ត្រូវតែបានធ្វើចំណាត់ថ្នាក់ជាឥណទានរយៈកាលខ្លី។

**ប្រការ ៦.-**

បើគ្រឹះស្ថានមួយបានផ្តល់ឥណទាន ឬ ទ្រព្យសកម្មច្រើនប្រភេទទៅឱ្យសមភាគីម្នាក់ ឬ មួយក្រុម ហើយមានឥណទាន ឬ ទ្រព្យសកម្មមួយត្រូវបានធ្វើការចាត់ថ្នាក់មិនល្អ ដូច្នេះគ្រឹះស្ថានត្រូវវាយតម្លៃឡើងវិញនូវឥណទានផ្សេងទៀត ដែលបានផ្តល់ទៅអតិថិជននោះ នឹងត្រូវធ្វើចំណាត់ថ្នាក់ឥណទានទាំងនោះទៅក្នុងប្រភេទដូចគ្នានឹងឥណទានដែលបានធ្វើចំណាត់ថ្នាក់រួចហើយ។ ការចាត់ថ្នាក់នេះត្រូវគិតបញ្ចូលទាំងកិច្ចសន្យាក្នុងខ្ទង់ក្រៅតារាងតុល្យការ លើកលែងតែកិច្ចសន្យានោះមិនតម្រូវឱ្យគ្រឹះ-ស្ថានទូទាត់សងប្រាក់។ ប៉ុន្តែ ផលប័ត្រពាណិជ្ជកម្ម រួមទាំងលិខិតឥណទានដែលបានទទួលធ្វើស្ថិការដោយបហារិត ហើយការទូទាត់សងបានទៀងទាត់ និងត្រឹមត្រូវអាចរក្សាចំណាត់ថ្នាក់ធម្មតាបាន។

## ជំពូក ៣
## ឥណទានរៀបចំឡើងវិញ

**ប្រការ ៧.-**

ការរៀបចំឥណទានឡើងវិញអាចត្រូវបានធ្វើចំពោះតែអ្នកខ្ចីណាដែលមានដំណើរការអាជីវកម្មល្អនាពេលខាងមុខ ហើយដែលកំពុងជួប ឬ រំពឹងថាជួបការលំបាកជាបណ្តោះអាសន្នក្នុងការសងត្រឡប់វិញនូវប្រាក់ដើម និង/ឬ ការប្រាក់។

**ប្រការ ៨.-**

គ្រឹះស្ថានត្រូវបានហាមឃាត់អនុវត្តការរៀបចំបំណុលឡើងវិញ ដោយគ្រាន់តែក្នុងគោលបំណងជៀសវាង :

- ការធ្លាក់ចំណាត់ថ្នាក់របស់ខ្លួនព្រោះតែចំណាត់ថ្នាក់ឥណទាន ឬ
- ការកើនឡើងនូវសំវិធានធនលើឥណទានបាត់បង់ ឬ

- បញ្ឈប់ការទទួលស្គាល់ចំណូលការប្រាក់លើមូលដ្ឋានបង្គរ ។

**ប្រការ ៩.-**

ឥណទានដែលនឹងត្រូវរៀបចំឡើងវិញ ត្រូវវិភាគលើមូលដ្ឋានទិសដៅអាជីវកម្ម និងសមត្ថភាពសងប្រាក់វិញរបស់អ្នកខ្ចីទៅតាមការព្យាករណ៍លំហូរសាច់ប្រាក់ថ្មី ដែលស្របតាមស្ថានភាពទីផ្សារនិងបច្ចុប្បន្នកម្មនៃទស្សនៈវិស័យអាជីវកម្ម ដោយផ្អែកលើសម្មតិកម្មជាក់ស្តែងនិងប្រុងប្រយ័ត្ន ។

**ប្រការ ១០.-**

ការរៀបចំឡើងវិញនៃឥណទាន ត្រូវធ្វើឡើងដោយក្រុមការងារមួយដែលត្រូវតែនៅដាច់ដោយឡែកពីក្រុមដែលទទួលខុសត្រូវលើដំណើរការឱ្យខ្ចី ។ ក្នុងករណីដែលការចូលរួមរបស់ភ្នាក់ងារ ឬបុគ្គលិកនៅក្នុងក្រុមដំណើរការឱ្យខ្ចីនេះមិនអាចជៀសបាននោះ ក្រុមប្រឹក្សាភិបាលនៃគ្រឹះស្ថានត្រូវតាមដានផ្ទាល់ឱ្យបានតឹងតែងលើការរៀបចំឡើងវិញនៃឥណទាន ។

**ប្រការ ១១.-**

បន្ទាប់ពីឥណទានត្រូវបានរៀបចំឡើងវិញ គ្រឹះស្ថានត្រូវចាត់ថ្នាក់ឥណទាននោះដូចខាងក្រោម :

- មិនល្អជាងក្រោមស្តង់ដារ សម្រាប់ឥណទានដែលពីមុនមកត្រូវបានចាត់ថ្នាក់ជាសង្ស័យ ឬ បាត់បង់
- មិនផ្លាស់ប្តូរសម្រាប់ឥណទានដែលពីមុនមកត្រូវបានចាត់ថ្នាក់ជាឥណទានធម្មតាឃ្លាំមើល ឬ ក្រោមស្តង់ដារ ។

ការចាត់ថ្នាក់នេះមិនត្រូវឱ្យល្អជាងមុនឡើយ លុះត្រាតែការប្រាក់ និងប្រាក់ដើម ត្រូវបានសងមកវិញក្នុងអំឡុងបីគ្រាសងរំលស់ និងក្នុងរយៈពេលមិនតិចជាងបីខែ ។ បន្ទាប់ពីរយៈពេលនេះ ឥណទានដែលត្រូវបានរៀបចំឡើងវិញអាចត្រូវបានចាត់ថ្នាក់ទៅតាមប្រការ ៤ នៃប្រកាសនេះ ។

## ជំពូក ៤

## ភាគពុកិច្ចធ្វើសំវិធានធន

**ប្រការ ១២.-**

គ្រឹះស្ថានទាំងអស់ ត្រូវរក្សាសំវិធានធនសម្រាប់ឥណទានបាត់បង់ឱ្យបានគ្រប់គ្រាន់ ដើម្បីទូទាត់ការខាតបង់ក្នុងសំពៀតឥណទានដែលអាចកើតឡើង ។

១- ពីរដងក្នុងមួយឆ្នាំ ឬ ញឹកញាប់ជាងនេះប្រសិនបើចាំបាច់ ក្រុមប្រឹក្សាភិបាលតម្រូវ

ឱ្យមានគណៈគ្រប់គ្រងវាយតម្លៃពីលទ្ធភាពប្រមូលបំណុលមកវិញនៃឥណទានទាំងអស់ រាប់បញ្ចូលទាំងការប្រាក់ដែលបានបង្គរ និងមិនទាន់បានសង ហើយត្រូវតែតម្រូវឱ្យមានការចុះបញ្ជីសមស្របដើម្បី (១) រាយការណ៍អំពីចំណូលឱ្យបានត្រឹមត្រូវ និង (២) ធានាថាការធ្វើសំវិធានធនសម្រាប់ឥណទានបាត់បង់ ត្រូវបានធ្វើគ្រប់គ្រាន់ដើម្បីទូទាត់សងការបាត់បង់ដែលអាចកើតមាន។ គណៈគ្រប់គ្រងត្រូវតែរក្សាការកត់ត្រាកំណត់ហេតុនៃការវាយតម្លៃនិងការចុះបញ្ជី និងផ្តល់ការកត់ត្រានិងបញ្ជីទាំងនោះមកធនាគារជាតិនៃកម្ពុជា សវនកម្មផ្ទៃក្នុង និងសវនករខាងក្រៅសម្រាប់ការត្រួតពិនិត្យដល់ទីកន្លែង។

២- ការកើនឡើង និងការថយចុះរបស់គណនីប្រាក់សំវិធានធនសម្រាប់ឥណទានបាត់បង់ ត្រូវបានធ្វើឡើងតាមរយៈការចុះទៅក្នុងគណនីចំណាយសំវិធានធនចំពោះឥណទានបាត់បង់នៅក្នុងរបាយការណ៍ចំណេញ-ខាត ។

៣- ក្នុងការកំណត់ការបាត់បង់ដែលអាចកើតមានចំពោះឥណទានណាមួយ ឬ ចំពោះសំពៀតឥណទានទាំងមូល រាល់កត្តាពាក់ព័ន្ធត្រូវតែបានយកមកពិចារណា រួមមានយ៉ាងហោចនូវប្រវត្តិបទពិសោធន៍ឥណទានបាត់បង់ពីមុន ស្ថានភាពសេដ្ឋកិច្ចបច្ចុប្បន្ន និន្នាការនានានៃការមិនសងបំណុល ប្រសិទ្ធភាពនៃគោលនយោបាយឱ្យខ្ចី និងនីតិវិធីនៃការប្រមូលបំណុលរបស់គ្រឹះស្ថាន និងភាពត្រឹមត្រូវនិងទាន់ពេលវេលាក្នុងការពិនិត្យឡើងវិញលើសំពៀតឥណទានរបស់គ្រឹះស្ថាន។

**ប្រការ ១៣.-**

សំវិធានធន ត្រូវធ្វើតាមសមាមាត្រអប្បបរមាស្របតាមចំណាត់ថ្នាក់ដែលបានកំណត់ដូចខាងក្រោម។ នៅពេលដែលមានព័ត៌មានដែលអាចទុកចិត្តបាន បញ្ជាក់ថាការបាត់បង់អាចច្រើនជាងចំនួនអប្បបរមានោះ សមាមាត្រនៃសំវិធានធនត្រូវធ្វើឡើងឱ្យកាន់តែធំជាងនេះ។

១- សំវិធានធនទូទៅ

- សម្រាប់ឥណទានថ្នាក់ "ធម្មតា" ១% នៃឥណទានដុលសរុប។

២- សំវិធានធនជាក់លាក់

- សម្រាប់ឥណទានថ្នាក់ "ឃ្លាំមើល" ៣% នៃឥណទានដុល
- សម្រាប់ឥណទានថ្នាក់ "ក្រោមស្តង់ដារ" ២០% នៃឥណទានដុល
- សម្រាប់ឥណទានថ្នាក់ "សង្ស័យ" ៥០% នៃឥណទានដុល
- សម្រាប់ឥណទានថ្នាក់ "បាត់បង់" ១០០% នៃឥណទានដុល។

**ប្រការ ១៤.-**

គ្រឹះស្ថាន ត្រូវរក្សាការកត់ត្រាឱ្យបានត្រឹមត្រូវ ដើម្បីជាការគាំទ្រដល់ការវាយតម្លៃឥណទានដែលអាចបាត់បង់ និងធ្វើសំវិធានធនឱ្យបានគ្រប់គ្រាន់សម្រាប់ឥណទានបាត់បង់។

សំវិធានធនជាក់លាក់ (specific provision) ត្រូវកត់ត្រានៅក្នុងគណនីរបស់គ្រឹះស្ថាន ហើយចាត់ទុកជាចំណាយនៅក្នុងរបាយការណ៍ចំណេញ-ខាត នៅក្នុងគ្រាដែលត្រូវធ្វើសំវិធានធននោះ។ សំវិធានធនមិនត្រូវធ្វើរំលស់នៅតាមគ្រានោះទេ។ នៅពេលណាដែលសមតុល្យគណនីរបស់អតិថិជនមានបញ្ចូលមូលធនកម្មការប្រាក់ដែលបានកត់ត្រាបដិភាគជាមួយការប្រាក់ព្យួរទុក មូលធនកម្មការប្រាក់នេះមិនត្រូវយកមកគិតសម្រាប់គណនាសំវិធានធនទេ។

ស្របតាមមូលដ្ឋានបង្គរនៃគណនេយ្យ (accrual basis accounting) ការប្រាក់បង្គរលើគណនីអតិថិជន ត្រូវបានកត់ត្រាជាចំណូលក្នុងគណនីចំណេញ-ខាត។ ប៉ុន្តែមិនត្រូវអនុវត្តតាមទម្រង់ការបែបនេះទេ ចំពោះទ្រព្យសកម្មទាំងឡាយណាដែលត្រូវបានចាត់ថ្នាក់ជាបំណុលក្រោមស្តង់ដារ បំណុលសង្ស័យ ឬបំណុលបាត់បង់។ ក្នុងស្ថានភាពនេះ ការប្រាក់បង្គរត្រូវកត់ត្រាខាងឥណទាននៃគណនីសម្រាប់ការប្រាក់ព្យួរ។

## ជំពូក ៥
## ការលុបចោលនូវឥណទាន និង បុរេប្រទាន

**ប្រការ ១៥.-**

គ្រឹះស្ថានត្រូវតែលុបឥណទាន និងបុរេប្រទាន ឬ មួយផ្នែកនៃឥណទានចេញពីតារាងតុល្យការរបស់ខ្លួន នៅពេលដែលគ្រឹះស្ថានបាត់សិទ្ធិតាមកិច្ចសន្យាគ្រប់គ្រងលើឥណទាន ឬ នៅពេលដែលឃើញថាឥណទានមួយផ្នែក ឬ ទាំងមូលមិនអាចប្រមូលវិញបាន ឬ គ្មានសង្ឃឹមថាឥណទាននេះអាចប្រមូលបានមកវិញទេ។ ជាទូទៅ ករណីដូចខាងក្រោម ជាសញ្ញាណអាចនាំទៅដល់ការលុបចោលឥណទាន ឬ មួយផ្នែកនៃឥណទាន :

ក- គ្រឹះស្ថានបាត់សិទ្ធិតាមកិច្ចសន្យាក្នុងការគ្រប់គ្រងឥណទានទាំងស្រុង ឬ មួយផ្នែកដូចដែលបានសម្រេចដោយតុលាការ

ខ- គ្រប់ប្រភេទនៃមូលប័ត្រ ឬ វត្ថុបញ្ចាំដែលត្រូវបានរឹបអូស និងលក់បញ្ចេញ ប៉ុន្តែមិនគ្រប់គ្រាន់សម្រាប់ទូទាត់សងឥណទានទាំងមូល

គ- គ្រឹះស្ថានមិនអាចប្រមូល ឬលែងមានមូលហេតុសមស្របក្នុងការធានាថានឹងប្រមូលឥណទានគ្រប់ចំនួនដែលត្រូវទារ ស្របតាមលក្ខខណ្ឌនៃកិច្ចសន្យាឥណទាន និងបុរេប្រទាន

ឃ- អ្នកខ្ចីប្រាក់បានក្ស័យធន ឬកំពុងតែស្ថិតនៅក្នុងដំណាក់កាលស្តារនីតិសម្បទា ផ្នែកហិរញ្ញវត្ថុ និងកំពុងតែជួបការលំបាកក្នុងការសងបំណុល

ង- ឥណទានត្រូវបានចាត់ថ្នាក់ជាប្រភេទឥណទានបាត់បង់។

រាល់គោលនយោបាយឥណទាន ត្រូវតែលំអិតឱ្យបានគ្រប់គ្រាន់អំពីនីតិវិធីនៃការលុបចេញពីបញ្ជីឥណទានដើម្បីបន្ថយឱ្យនៅជាអប្បបរមានៃការរំលោភផ្សេងៗ។

## ជំពូក ៦
## ការត្រួតពិនិត្យឥណទាន

**ប្រការ ១៦.-**

នៅពេលអនុវត្តការត្រួតពិនិត្យដល់ទីកន្លែង ធនាគារជាតិនៃកម្ពុជាពិនិត្យឡើងវិញនូវគោលការណ៍និងដំណើរការចាត់ថ្នាក់ទ្រព្យសកម្ម និងអាចចាត់ថ្នាក់ទ្រព្យសកម្មអនុលោមតាមបញ្ញត្តិដែលបានចែងក្នុងប្រកាសនេះ។ ទ្រព្យសកម្មដែលត្រូវបានចាត់ថ្នាក់ក្នុងអំឡុងពេលនេះ ត្រូវរក្សាទុកក្នុងប្រភេទដែលធនាគារជាតិនៃកម្ពុជាបានវាយតម្លៃ រហូតទាល់តែបានបំពេញលក្ខខណ្ឌទាំងអស់ទើបអាចចាត់ថ្នាក់ទៅក្នុងប្រភេទមួយផ្សេងទៀត។ ក្រុមប្រឹក្សាភិបាល និងអ្នកគ្រប់គ្រងជាន់ខ្ពស់នៃគ្រឹះស្ថានត្រូវតែចាត់វិធានការគ្រប់គ្រាន់ជាបន្ទាន់រហូតដល់បទប្បញ្ញត្តិ ត្រូវបានប្រតិបត្តិតាមពេញលេញ រួមមានការកែសម្រួលគោលការណ៍ នីតិវិធី និងដំណើរការអនុវត្ត។

**ប្រការ ១៧.-**

សវនករខាងក្រៅ ត្រូវពិនិត្យឡើងវិញនូវគោលនយោបាយ នីតិវិធី និងដំណើរការចាត់ថ្នាក់ទ្រព្យសកម្មនៅពេលធ្វើសវនកម្មតាមគ្រារបស់ខ្លួន។ សវនករខាងក្រៅ ត្រូវវាយតម្លៃដោយផ្អែកលើការអង្កេត ការប្រតិបត្តិតាមគោលនយោបាយនិងបទបញ្ជាផ្ទៃក្នុង ដែលបានដាក់ចេញដោយក្រុមប្រឹក្សាភិបាល និងអ្នកគ្រប់គ្រងជាន់ខ្ពស់ ព្រមទាំងគុណភាពនៃការចាត់ថ្នាក់ទ្រព្យសកម្ម ដែលបានអនុវត្តដោយគ្រឹះស្ថាន។

ផ្អែកតាមការអង្កេត សវនករខាងក្រៅ ត្រូវវិនិច្ឆ័យលើភាពត្រឹមត្រូវនៃចំណូលដែលបានទទួលស្គាល់លើភាពគ្រប់គ្រាន់នៃសំវិធានធនដែលបានអនុវត្ត លើគុណភាពនិងឯករាជ្យភាពនៃការវាយតម្លៃវត្ថុធានាដែលត្រូវបានអនុវត្តទាំងផ្ទៃក្នុងនិងពីខាងក្រៅ។ សវនករខាងក្រៅ ត្រូវចងក្រងឯកសារសំខាន់ៗដែលមានផលប៉ះពាល់ដល់ចំណូលដែលត្រូវបានទទួលស្គាល់ និងលើស្ថានភាពសាធនភាពរបស់គ្រឹះស្ថាន។ សវនករខាងក្រៅ ក៏ត្រូវយកចិត្តទុកដាក់ជាពិសេស ទៅលើការចាត់ថ្នាក់ទ្រព្យសកម្មដែល

ទាក់ទងនឹងប្រាក់កម្ចី និង ឥណទានផ្សេងទៀតដែលបានផ្តល់ទៅឱ្យបុគ្គលសម្ព័ន្ធនិងភាគីសម្ព័ន្ធញាតិ ដោយត្រូវមានផ្តល់យោបល់ជាក់លាក់នៅក្នុងរបាយការណ៍ដែលបានផ្តល់ជូនធនាគារជាតិនៃកម្ពុជា ។

**ប្រការ ១៨.-**

សវនករផ្ទៃក្នុង ត្រូវពិនិត្យឡើងវិញតាមគ្រាលើសំពៀតទ្រព្យសកម្មទាំងមូល ។ ការពិនិត្យឡើងវិញនោះ ត្រូវបានអនុវត្តទូលំទូលាយយ៉ាងតិចមួយឆ្នាំម្តង ។ នៅពេលអនុវត្តការពិនិត្យឡើងវិញកាន់តែញឹកញាប់ នៅពេលនោះសវនករផ្ទៃក្នុង ត្រូវប្រើប្រាស់វិធីសាស្ត្រជ្រើសរើសជាន់គំរូ ។ ប៉ុន្តែចំពោះហានិភ័យធំៗ សវនករផ្ទៃក្នុងត្រូវពិនិត្យឡើងវិញជាប្រព័ន្ធ ។

សវនករផ្ទៃក្នុង ត្រូវវាយតម្លៃដោយផ្អែកលើការអង្កេតផ្ទាល់ខ្លួននិងដោយឯករាជ្យនូវការប្រតិបត្តិតាមគោលនយោបាយនិងបទបញ្ជាផ្ទៃក្នុង ដែលបានដាក់ចេញដោយក្រុមប្រឹក្សាភិបាល និងអ្នកគ្រប់គ្រងជាន់ខ្ពស់ ព្រមទាំងគុណភាពនៃការចាត់ថ្នាក់ទ្រព្យសកម្មដែលបានអនុវត្តដោយគ្រឹះស្ថាន ។

សវនករផ្ទៃក្នុង ត្រូវវិនិច្ឆ័យភាពត្រឹមត្រូវនៃចំណូលដែលបានទទួលស្គាល់ លើភាពគ្រប់គ្រាន់នៃសំវិធានធនដែលបានអនុវត្ត លើគុណភាពនិងឯករាជ្យភាពនៃការវាយតម្លៃវត្ថុធានាដែលត្រូវបានអនុវត្តទាំងផ្ទៃក្នុងនិងពីខាងក្រៅ ។ សវនករផ្ទៃក្នុង ត្រូវបញ្ជូនជាបន្ទាន់នូវបញ្ហាសំខាន់ៗជូនទៅក្រុមប្រឹក្សាភិបាលដើម្បីមានអនុសាសន៍ចាត់វិធានការកែតម្រូវគ្រប់គ្រាន់ ដើម្បីដោះស្រាយបញ្ហាដែលបានលើកឡើងឱ្យបានឆាប់រហ័ស ។

ជាចុងក្រោយ សវនករផ្ទៃក្នុង ក៏ត្រូវវិនិច្ឆ័យពីគុណភាពនៃប្រព័ន្ធគ្រប់គ្រងព័ត៌មាន ដែលបានរៀបចំឡើង ដើម្បីត្រួតពិនិត្យហានិភ័យឥណទាននិងគោលបំណងនៃការធ្វើសេចក្តីសម្រេច ក៏ដូចជាលើភាពត្រឹមត្រូវ និងការបញ្ជូនទិន្នន័យបានទាន់ពេលវេលាទៅអ្នកគ្រប់គ្រងគ្រឹះស្ថាន ។

## ជំពូក ៧

## អវសានប្បញ្ញត្តិ

**ប្រការ ១៩.-**

ត្រូវចាត់ទុកជានិរាករណ៍ប្រកាសដូចខាងក្រោមនេះ :

- ប្រកាស ធ៧-០០-៥១ ស្តីពីចំណាត់ថ្នាក់ និងសំវិធានធនលើបំណុលអាក្រក់ និងបំណុលសង្ស័យ រួមទាំងការប្រាក់ដែលបានព្យួរ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០០ ។
- ប្រកាស ធ៧-០២-១៤៥ ស្តីពីចំណាត់ថ្នាក់ និងសំវិធានធនលើបំណុលអាក្រក់ និងបំណុលសង្ស័យ រួមទាំងការប្រាក់ដែលបានព្យួរ ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០២ ។

**ប្រការ ២០.-**

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា និងគ្រប់នាយកដ្ឋានរបស់ធនាគារជាតិនៃកម្ពុជា និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមឱវាទ និងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជាត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ២១.-**

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ភ្នំពេញ ថ្ងៃទី [illegible] ខែកុម្ភៈ ឆ្នាំ២០០៩

ទេសាភិបាល

ជា-ចាន់តូ

**កន្លែងទទួល**

- ដូចប្រការ ២០ "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ

**ចម្លងជូន**

- សមាជិកក្រុមប្រឹក្សាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជ្រាបជាព័តិមាន"
- នាយកដ្ឋានរដ្ឋបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីចុះផ្សាយក្នុងរាជកិច្ច"

KINGDOM OF CAMBODIA
NATION RELIGION KING

NATIONAL BANK OF CAMBODIA

Number B7.09 - 074 Prokor

**Unofficial Translation**

# PRAKAS
## ON
## ASSET CLASSIFICATION AND PROVISIONING IN BANKING AND FINANCIAL INSTITUTIONS

**The Governor of the National Bank of Cambodia**

- With reference to the Constitution of the Kingdom of Cambodia;
- With reference to the Royal Kram NS/RKM/0196/27 of January 26, 1996 promulgating the Law on the Organization and Functioning of the National Bank of Cambodia;
- With reference to the Royal Kram NS/RKM/1206/036 of December 29, 2006 promulgating the Law on the amendment of articles 14 and 57 of the Organization and Functioning of the National Bank of Cambodia;
- With reference to the Royal Kram NS/RKM/1199/13 of November 18, 1999 promulgating the Law on Banking and Financial Institutions;
- With reference to the Royal Decree NS/RKT/0508/526 of May 13, 2008 on the reappointment of His Excellency Chea Chanto as Governor General of the National Bank of Cambodia, equivalent to Senior Minister;
- Pursuant to the recommendation made by National Bank of Cambodia management during the February 23, 2009 meeting.

**Decides:**

## Chapter I
## General Provisions

**Article 1:** This Prakas is intended to ensure that all loans and assets of banking and financial institutions, hereinafter called "Institutions," are regularly evaluated using an objective and prudential grading system, and that timely and appropriate provisions and write-offs are made to the reserve for loan loss account in order to accurately reflect the true condition and operating results of the institutions.

This Prakas applies to all loans, advances and similar assets, including the ones extended to affiliates and related parties held or reflected in the Institution's balance sheet.

Given the potential impacts of non performing loans on the solvency, liquidity and income condition of the Institution, senior management and the board should exercise risk-based and forward looking judgment based on the observed trends of classified assets.

**Article 2:**
**"Capitalized interest"** means any accrued and uncollected interest which has been added to the principal amount of a loan at a payment date or at maturity; capitalized interest also includes unpaid interest which is refinanced or rolled over into a new loan.
For purposes of this Prakas, capitalization of interest will not be permitted unless:

- the borrower has the ability to repay the full debt (principal plus interest) in the normal course of business;
- the interest capitalization was anticipated upon approval of the initial loan based on the borrowers planned temporary lack of cash flow;
- repayment, including capitalized interest, is based on a reasonably ascertainable future event.

**"In the process of collection"** means that collection of a debt is proceeding in due course in a timely manner either through:

- legal action, including the enforcement of judgments against the borrower; or
- through collection efforts not involving legal action but which are reasonably expected to result in full repayment of the debt within 90 days or in restoration of the debt to a current status through payment of outstanding arrears.

**"Loans" and "loans and advances"** may be used interchangeably to include any loan, discount, advance, overdraft, export bills purchased, other bills receivable or purchased, import bills, a customer's liability on acceptances or any other credit facilities extended to the customer of an institution.

**"Non-performing"** means that an asset is no longer generating income. For purposes of this Prakas, "non-performing" assets are classified as substandard, doubtful or loss.

Current accounts used for overdraft purposes and other credit extensions not having pre-established repayment programs are considered "non-performing" when any of the following conditions exist:

- debt exceeds the customer's approved limit for 90 consecutive days or more;
- the customer's borrowing line has expired for 90 days or more;
- interest is due and unpaid for 90 days or more; or
- the current account has been inactive for 90 days, *or deposits are insufficient to cover the outstanding interest during the period.*

**"Off balance sheet items"** means all items not shown on the balance sheet but which constitute credit risk. Such risks include guarantees, acceptances, performance bonds, letters of credit, and all other off balance sheet items deemed to constitute credit risk by the National Bank of Cambodia.

**"Past due" or "overdue"** means any loan for which:

- principal or interest is due and unpaid for 30 days or more; or
- interest payments equal to 30 days interest or more have been capitalized, refinanced, or rolled over.

Current accounts use for overdrafts purposes and other credit extensions which do not have pre-established repayment schedules are considered "past due" when any of the conditions below exist:

- debt exceeds the customer's approved limit for 30 consecutive days or more;
- the customer's borrowing line has expired for 30 days or more;
- interest is due and unpaid for 30 days or more; or
- the current account has been inactive for 30 days, or deposits in the current account used are insufficient to cover the interest capitalized during the period.

**"Provision for Loan Losses" or "Loan Loss Provision"** means an income statement account used to increase or decrease the allowance for Loan Losses in order to maintain that account at a level adequate to absorb expected losses in the loan portfolio.

**"Reserve for Loan Losses" or "Allowance for Loan Loses"** means a balance sheet valuation account established through charges to "provision expense" in the income statement and against which uncollectible loans or portions thereof are written-off. The allowance for the loan losses account is offset by loans for financial reporting purposes.

**"Renegotiated loan"** or **"Restructured Loan"** means any loan that has been rescheduled or refinanced in accordance with an agreement setting forth a new repayment schedule on a periodic basis occasioned by weaknesses in the borrower's financial condition and/or inability to repay the loan as originally agreed.

## Chapter II
## Classification of Loans and Assets

**Article 3** - All loans and assets shall be classified according to the repayment capacity of the counterparty. This repayment capacity is assessed through the following criteria:

- Past payment experience,
- Financial condition of the borrower, both current and expected,
- Business prospective and cash-flow projections, based on realistic and prudent assumptions,
- Ability and willingness to repay of the borrower,

- Financial environment,
- Quality of documentation.

A significant departure from the primary source of repayment may warrant adverse classification even when a loan is current or appears to be supported by underlying collateral value. Reclassification may also be warranted if the counterparty could not meet the conditions of the contract and needed a modification of terms, refinancing, or additional advances.

In cases where different classification grades may be assigned based on subjective criteria, the more severe classification should apply. Moreover, nothing contained in the classification definitions indicated in Article 4 below shall preclude assigning a more severe grade when an analysis of a borrower's financial condition, ability, and willingness to repay justifies the more severe classification.

**Article 4** - All assets shall be classified into five categories as follows:

(i) **Normal.** Assets in this category are fully protected by the current sound worth and paying capacity of the counterparty, are performing in accordance with contractual terms, and are expected to continue doing so.

(ii) **Special mention.** Assets in this category shall be currently protected and shall not be past due but exhibit potential weaknesses which shall, if not corrected, weaken the asset or inadequately protect the bank's position at some future date. Examples of such weaknesses include, but are not limited to: inability to properly supervise due to an inadequate loan agreement; deteriorating condition or control of collateral; deteriorating economic conditions or adverse trends in the borrower's financial position which shall, if not checked, jeopardize repayment capacity, potential risk is greater than when the loan was originally granted. This category should not be used as a compromise between Normal and Substandard.

Overdrafts must be classified as Special mention, if excess of the approval limit is more than 30 days but less than 90 days, or the current account has been inactive for 30 days, or deposits in the current account used are insufficient to cover the interest capitalized during the period.

Any loan which is past due 30 days or more but less than 90 days shall be classified as Special mention or worse.

When interest payments for 30 to 90 days have been capitalized, refinanced, or rolled over into a new loan, this loan shall be classified as Substandard or worse.

(iii) **Substandard.** Assets in this category are not adequately protected by the current sound worth and paying capacity of the counterparty. In essence, the primary source(s) of repayment is not sufficient to service the debt and the bank must look to secondary sources such as collateral, sale of fixed assets, refinancing, or additional capital injections for repayment. Substandard assets have well-defined weaknesses that jeopardize the orderly repayment of the debt.

Overdrafts must be classified as Substandard if excess of the approval limit is more than 90 days,

or if there are overdrafts with no significant amount in credit during 90 days or more, or the current account has been inactive for 90 days, or deposits in the current account used are insufficient to cover the interest capitalized during the period.

Any loan which is past due 90 days or more but less than 180 days shall be classified as Substandard at a minimum.

When interest payments for 90 to 180 days have been capitalized, refinanced, or rolled over into a new loan, this loan shall be classified as Substandard or worse.

(iv) **Doubtful**. Assets in this category have all the weaknesses inherent in a substandard asset plus the added characteristic that the asset is not well secured. These weaknesses make collection in full, on the basis of currently existing facts, conditions, and value, highly questionable and improbable. The possibility of loss is high, but because of important and reasonably specific pending factors that mitigate, the actual amount of loss cannot be fully determined. If pending events do not occur within 180 days and repayment must again be deferred pending further developments, a Loss classification is warranted upon realisation of securities held.

Overdrafts must be classified as Doubtful, if excess of the approval limit is more than 180 days, or if there are overdrafts with no significant amount in credit during 180 days or more, or the current account has been inactive for 180 days, or deposits in the current account used are insufficient to cover the interest capitalized during the period.

Any loan which is past due 180 days or more shall be classified as doubtful or worse.

When interest payments for 180 to 360 days have been capitalized, refinanced, or rolled over into a new loan, this loan shall be classified as Doubtful or worse.

(v) **Loss**. Assets that are considered uncollectible or of such little value that their continuance as bankable asset is not warranted shall be classified Loss. Losses shall be taken in the period in which they are identified, or should have been identified, as uncollectible.

Overdrafts must be classified as Loss, if excess of the approval limit is more than 360 days, or if there are overdrafts with no significant amount in credit during 360 days or more, or the current account has been inactive for 360 days, or deposits in the current account used are insufficient to cover the interest capitalized during the period.

Any loan which is past due 360 days or more shall be classified as Loss.
When interest payments for 360 days or more have been capitalized, refinanced, or rolled over into a new loan, this loan shall be classified as Loss.

**Article 5 -** Overdrafts, whatever their maturity, must be used only to fund short term needs. Overdrafts shall be classified as short term loans.

**Article 6 -** If a bank has multiple loans or assets outstanding with a single counterparty or group of counterparties and one loan or another asset meets the criteria for being adversely

classified, then the bank shall evaluate every other loan to that borrower shall, classify them in the same category. This includes off balance sheet commitments, except where the nature of these commitments makes it unlikely that the bank will have to make any disbursement. However, commercial paper, including documentary credit, accepted by the drawee and where timely payment is likely can be maintained in the Normal category.

## Chapter III
## Restructured Loans

**Article 7 -** Debt Restructuring may only be undertaken towards debtors that still have good business prospects and have or are expected to experience **temporary** difficulties in repayment of credit principal and/or interest.

**Article 8 -** Banks are prohibited from conducting Debt Restructuring merely for the purpose of avoiding:

- downgrading in classification of credit; or
- formation of increased Allowance for Earning Assets Losses; or
- **Discontinued** recognition of interest income on an accrual basis.

**Article 9 -** Credit to be restructured shall be analyzed on the basis of the business prospects and repayment capacity of the debtor according to **new** cash flow projections supported by updated business perspectives and overall market conditions being based on realistic and prudent assumptions.

**Article 10 -** Debt Restructuring shall be carried out by a work-out unit which shall be separate from the units responsible for the lending process. In the case that involvement of officers or employees involved in the lending process is unavoidable; the Board of Directors of the Institution shall conduct direct and strict monitoring of the implementation of Debt Restructuring.

**Article 11 -** Following the completion of Debt Restructuring, the credit shall be classifed as follows:

- not better than Substandard, for credit originally classified as doubtful or loss;
- unchanged, for credit originally classified as normal, special mention or substandard.

This classification shall not be improved unless there are no arrears in repayment of principal and interest within three (3) installment periods and within a period of not less than three (3) months. After that period, the restructured credit may be classified according to article 11 of this Prakas.

## Chapter IV
## Provisioning Requirements

**Article 12 -** All institutions shall maintain a Allowance for Loan Losses at a level adequate to absorb expected losses in the loan portfolio.

1- Twice a year, or more frequently if warranted, the board of directors shall require management to evaluate the collectibility of all loans, including any accrued and unpaid interest, and shall require that appropriate entries be made to (i) accurately report earnings, and (ii) assure that the Provision for Loan Losses is adequate to absorb potential losses. Management must maintain reasonable records in support of their evaluations and entries and shall make them available for on-site inspection by NBC examiners, external auditors and Internal Audit.

2- Increases and decreases in the Allowance for Loan Losses account shall be made through charges to the Provision for Loan Losses in the income statement.

3- In determining the amount of potential loss in specific loans or in the aggregate loan portfolio, all relevant factors shall be considered, including, but not limited to: historical loan loss experience, current economic conditions, delinquency trends, the effectiveness of the bank's lending policies and collection procedures, and the timeliness and accuracy of its loan review function.

**Article 13 -** The following minimum percentage amounts for provisioning are to be maintained according to assigned classifications. Where reliable information suggests that losses are likely to be more than these minimum amounts, larger provisions shall be made.

| | | |
|---|---|---|
| (i) | General provision | |
| | - for loans graded "**Normal**" | 1% of gross loan |
| (ii) | Specific provision | |
| | - for loans graded "**Special mention**" | 3% of gross loan |
| | - for loans graded "**Substandard**" | 20% of gross loan |
| | - for loans graded "**Doubtful**" | 50% of gross loan |
| | - for loans graded "**Loss**" | 100% of gross loan. |

**Article 14-** Institutions shall maintain adequate records supporting their evaluations of potential loan losses and the entries made to ensure adequacy of the Provision for Loan Losses.

The specific provision shall be recorded in the Institution's accounts and charged to the profit and loss account in the month in which the need is identified. It shall not be spread over future periods. Insofar as the customer account balance includes an amount of interest the counterpart of which has been recoded as interest in suspense, this amount shall not be taken into account in calculating the specific provision.

In accordance with accrual basis accounting, interest accrued on a customer account shall be recorded as income in the profit and loss account. However, such a procedure is not followed for assets once they have been classified as Substandard, Doubtful or Loss. In these circumstances, interest accrued shall be credited to an account for interest in suspense.

## Chapter V
## Write-off of Loans/Advances

**Article 15 -** An institution should remove a loan/advance or a portion of a loan from its balance sheet when the bank loses control of the contractual rights over the loan or when all or part of a loan is deemed uncollectable; or there is no realistic prospect of recovery. This is normally evident at a stage where-

a- The bank has lost control over the contractual rights that comprise the loan or part of the loan as determined by a court of law.

b- All forms of securities or collateral have been called, realized but proceeds failed to cover the entire facility outstanding.

c- The bank is unable to collect or there is no longer reasonable assurance that the bank will collect all amounts due according to the contractual terms of the loan/advances agreement.

d- The borrower becomes bankrupt or is undergoing other forms of financial restructuring and is having difficulty in servicing the facility.

e- The loan is classified under loss category.

All credit policies should adequately detail the write-off procedures in order to minimize potential abuse.

## Chapter VI
## Loans Control

**Article 16** When performing an on-site examination, NBC will review asset classification processes and policies and may classify assets in accordance with the provisions set under this Prakas. The assets classified during such a process shall remain in the categories assessed by the NBC until all the conditions for re-classification are met. The Board of Directors and Senior Management should swiftly take all measures to be fully compliant with the regulatory requirements, including possible revision of policies, procedures and processes.

**Article 17** The External Auditors (Certified Public Accountants) are required to review the asset classification policies, procedures and processes in the course of their periodic due diligences. They shall assess, based on their investigations, internal compliance with the policies and rules set by the Board of Directors and Senior Management as well as the overall quality of the asset classification performed at the banks.
Based on their investigations, External Auditors shall make a judgment on accuracy of recognized income, on adequacy of provisioning performed, on quality and independence of collateral appraisals performed externally and internally. They should document any material element that has an impact on recognized income and on the solvency condition of the bank. Special attention shall be paid to asset classification related to loans and facilities extended to related parties and affiliates; those should lead to specific comments in the reports issued and sent to the NBC / Banking Regulatory Authority.

**Article 18** The Internal Audit shall perform periodic reviews of the overall portfolio. Such reviews shall be carried out at least once a year in a comprehensive manner. Where such reviews are performed more frequently, they might then be performed by making use of sampling techniques. However, the bigger exposures shall be systematically reviewed.

Internal Audit shall assess, based on its own independent investigations, internal compliance with the policies and rules set by the Board of Directors and Senior Management as well as the overall quality of the asset classification performed at the bank.

Based on its investigations, Internal Audit shall make a judgment of the accuracy of recognized income, on adequacy of provisioning performed, on quality, the selection and the effectiveness of institution's rights on pledged assets for collateral accepted as a credit risk mitigation element. Any significant issue shall be immediately brought to the Board's attention and lead to a recommendation of corrective actions to be taken to rapidly solve the raised issues.

Ultimately, Internal Audit shall also judge the quality of the Management Information System designed for credit risk monitoring and decision making purposes as well as the accuracy and timely delivery of data provided to Bank Management.

## Chapter VII
## Final Provisions

**Article 19 -** The following regulations:

Prakas B7-00-51 on the Classification of and provisions for bad and doubtful debts, including interests in suspense, dated February 17, 2000,

Prakas B7-02-145 on the Classification of and provisions for bad and doubtful debts, including interests in suspense, dated June 7, 2002,

are hereby repealed.

**Article 20 -** The General Directorate, the General Secretariat, the General Inspection, the General Cashier and all Departments of the National Bank of Cambodia, and all Banking and Financial Institutions under the NBC's supervisory authority shall strictly implement this Prakas.

**Article 21 -** This Prakas shall take effect from the signing date.

Phnom Penh, February 25, 2009
**The Governor**

cc:
- All members of the Board of Directors
- The parties concerned as stated in Article 20
- File
- CM "for info"
- Administration Department of CM
  "for publication in the National Gazette"